ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧៤០៧ អយក. បាវ

ថ្ងៃព្រហស្សតិ៨ធាងខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៦

ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពរដ្ឋបាលកណ្តាល**
- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**
- **លោក លោកស្រី ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រី នាយក នាយិកា សាលារៀនសាធារណៈគ្រប់កម្រិត**

កម្មវត្ថុ ៖ ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «**ថ្នាលគ្រប់គ្រងទិន្នន័យអប់រំ** (EDMP-Education Data Management Platform) **លើមុខងារគ្រប់គ្រងធនធានមនុស្ស** (HRM)»។

យោង ៖ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦ របស់នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលបានកំណត់ការកែលម្ម និងការពង្រឹងអភិបាលកិច្ចជាស្នូល ដើរទន្ទឹមគ្នានឹងការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ ដែលជាកិច្ចការអាទិភាពគន្លឹះ ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលនយោបាយជាតិ។ ទន្ទឹមនេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជំរុញការធ្វើបរិវត្តកម្មឌីជីថល ក្នុងការលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពលើការគ្រប់គ្រងនិងការផ្តល់សេវាអប់រំ។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍ «**ថ្នាលគ្រប់គ្រងទិន្នន័យអប់រំ** (EDMP-Education Data Management Platform **លើមុខងារគ្រប់គ្រងធនធានមនុស្ស** (HRM)» ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងព័ត៌មានបុគ្គលិកអប់រំតាមប្រព័ន្ធឌីជីថល ដោយធានាបាននូវភាពត្រឹមត្រូវ ភាពពេញលេញ និងបច្ចុប្បន្នភាពនៃទិន្នន័យ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការប្រមូល ការរក្សាទុក គ្រប់គ្រង តាមដាន និងវិភាគទិន្នន័យបុគ្គលិកអប់រំក្នុងការគាំទ្រលើការរៀបចំផែនការ គ្រប់គ្រងធនធានមនុស្ស និងការសម្រេចចិត្តប្រកបដោយភាពប្រាកដនិយម។ ក្នុងន័យនេះ ក្រសួងសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

ទំព័រទី ១

នូវ «**ប្លាលគ្រប់គ្រងទិន្នន័យអប់រំ (EDMP-Education Data Management Platform លើមុខងារគ្រប់គ្រងធនធានមនុស្ស (HRM)**» ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

ចម្លងជូន៖
-អគ្គលេខាធិការដ្ឋាន
-ខុទ្ទកាល័យ ឯកឧត្តម បណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ